# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# សវនាការអតីតប្រធានគណបក្សជំទាស់ គួរត្រូវបានអនុញ្ញាតឱ្យមានការចូលរួមពីក្រុមគ្រួសារ អ្នកសារព័ត៌មាន និងអង្គការសង្គមស៊ីវិល

ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលមានរាយនាមដូចខាងក្រោម សូមស្នើសុំឱ្យសាលាដំបូងរាជធានីភ្នំពេញ ធានាថា សវនាការរបស់ឯកឧត្តម កឹម សុខាអតីតប្រធានគណបក្សជំទាស់ដែលត្រូវបានរង់ចាំអស់រយៈពេលជាយូរមកហើយ គួរតែបើកទូលាយដល់សាធារណជន  សារព័ត៌មាន និងការចូលរួមពេញលេញពីសំណាក់អង្គការសង្គមស៊ីវិល។ យើងខ្ញុំក៏ស្នើសុំដល់តុលាការឱ្យផ្ដិតយកទិដ្ឋភាព និងផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការនេះ ដូចដែលបានធ្វើឡើងកាលពីលើកមុន។

សវនាការរបស់ឯកឧត្តម កឹម សុខា លើការចោទប្រកាន់ពី "បទសន្ទិដ្ឋិភាពជាមួយបរទេស" មិនទាន់បានបង្ហាញជាសាធារណៈនូវភស្តុតាងគួរឱ្យជឿទុកចិត្តណាមួយនៅឡើយទេ ហើយករណីនេះអាចប្រឈមនឹងការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររហូតដល់៣០ឆ្នាំ ដែលមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់សាធារណជនទាំងក្នុងនិងក្រៅប្រទេស។

ការចោទប្រកាន់នេះជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងការរំលាយអតីតគណបក្សជំទាស់ធំជាងគេនៅកម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ២០១៧គឺ គណបក្សសង្គ្រោះជាតិ ដែលដឹកនាំដោយឯកឧត្តម កឹម សុខា  ទោះបីជាគណបក្សនេះ ត្រូវបានបោះឆ្នោតគាំទ្រដោយ ប្រជាពលរដ្ឋកម្ពុជាជាង៤០%  កាលពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ក៏ដោយ។ ឯកឧត្តម កឹម សុខា អាយុ៦៥ឆ្នាំ ត្រូវបានចាប់ខ្លួននៅពាក់កណ្តាលអាធ្រាត្រ កាលពីខែកញ្ញា ឆ្នាំ២០១៧ ហើយត្រូវបានឃុំខ្លួនក្នុងពន្ធនាគារជាង១ឆ្នាំ បន្ទាប់មកត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយមានលក្ខខណ្ឌតឹងរឹងបំផុត (ឃុំខ្លួនក្នុងគេហដ្ឋាន) របស់ឯកឧត្តម ក្នុងខែកញ្ញា ឆ្នាំ២០១៨។

មិនមានសារព័ត៌មាន ឬអង្គការសង្គមស៊ីវិល ត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការ ដែលត្រូវបានប៉ាន់ប្រមាណថា នឹងត្រូវចំណាយពេលរហូតដល់៣ខែនេះទេ។ អ្នកសារព័ត៌មានឯករាជ្យពីរនាក់ ដែលបានរាយការណ៍ព័ត៌មានស្តីពីសវនាការនាព្រឹកនេះ ក្រោយមកត្រូវបានបដិសេធមិនឱ្យចូលបន្ទប់សវនាការនៅពេលរសៀលវិញ។ ការសម្រេចចិត្តបដិសេធចំពោះអ្នកសារព័ត៌មានទាំងពីរនាក់ បង្ហាញពីឆន្ទៈពិតប្រាកដរបស់អាជ្ញាធរ នៅពីក្រោយដំណើរការរឹតបណ្តឹងក្នុងការចុះឈ្មោះចូលរួមតាមដានសវនាការនេះ ដើម្បីរារាំងអ្នកសារព័ត៌មាន និងអង្គការសង្គមស៊ីវិល ក៏ដូចជាក្រុមគ្រួសាររបស់ឯកឧត្តម ទោះបីជាមានកៅអីទំនេរនៅក្នុងបន្ទប់សវនាការក៏ដោយ។

លោក ម៉ៃ ទិត្យថារ៉ា នាយកប្រតិបត្តិនៃសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ខេមបូចា បានមានប្រសាសន៍ថា៖ "តុលាការគួរតែអនុញ្ញាតឱ្យអ្នកសារព័ត៌មានចូលក្នុងបន្ទប់សវនាការ ដើម្បីអាចឱ្យអ្នកទាំងនោះរាយការណ៍ពិតប្រាកដពីអ្វីដែលបានកើតឡើង ជាជាងរង់ចាំទទួលព័ត៌មានបន្តពីអ្នកដទៃ។"

លោកបានបន្ថែមថា៖ "ប្រសិនបើកៅអីក្នុងបន្ទប់សវនាការមានចំនួនកំណត់ តុលាការគួរតែផ្សាយបន្តផ្ទាល់ដំណើរការជំនុំជម្រះក្តី ព្រោះនេះជាសម័យឌីជីថល"។ ហើយ "ដើម្បីស្តារលំហរប្រព័ន្ធផ្សព្វផ្សាយឱ្យបានល្អប្រសើរ តុលាការគួរតែផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគាត់"។

ការរាយការណ៍បឋមពីសវនាការបានរកឃើញថា ទោះបីជាមន្ត្រីតុលាការអះអាងថា មានចំនួនកៅអីសម្រាប់ត្រឹមតែ៣០នាក់ ប៉ុន្តែជាក់ស្តែងបន្ទប់សវនាការអាចដាក់មនុស្សបានច្រើនជាង៦០នាក់ទៅទៀត។

យើងខ្ញុំ សូមស្នើសុំដោយទទូចដល់តុលាការ សូមអនុញ្ញាតឱ្យក្រុមគ្រួសារឯកឧត្តម កឹម សុខា សារព័ត៌មាន និងអង្គការសង្គមស៊ីវិល ក៏ដូចជាស្នើឱ្យមានការផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការ ដើម្បីធ្វើឱ្យប្រាកដថា ការជំនុំជម្រះក្តីនេះប្រព្រឹត្តទៅដោយមានការបើកទូលាយ តម្លាភាព និងមានការចូលរួមដោយពេញលេញពីសាធារណជនទូទៅ៕

**សេចក្តីថ្លែងការណ៍នេះ គាំទ្រដោយ៖**

១. សហគមន៍កៅពីរ (ភ្នំពេញ)

២. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

៣. សហគមន៍អណ្ដូងថ្ម (ព្រះសីហនុ)
៤. សហគមន៍អន្លង់រុន (បាត់ដំបង)
៥. សហគមន៍បាតខ្ទះ (ព្រះសីហនុ)
៦. សហគមន៍បឹងប្រាំ (បាត់ដំបង)
៧. សហគមន៍បុរីកីឡា (ភ្នំពេញ)
៨. អង្គការព្រះពុទ្ធសាសនាសម្រាប់សន្តិភាព (BPO)
៩. សហគមន៍សេ អ៊ី ប្រាំ (ព្រះសីហនុ)
១០. អនាគតយុវជនកម្ពុជាអាស៊ាន (CamASEAN)
១១. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១២. បណ្ដាញព្រះសង្ឃយុវជនកម្ពុជា (CYMN)
១៣. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
១៤. សម្ព័ន្ធសហជីពកម្ពុជា (CATU)
១៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៦. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
១៧. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
១៨. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA)
១៩. សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ខេមបូចា (CamboJA)
២០. សហភាពការងារកម្ពុជា (CLC)
២១. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
២២. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
២៣. បណ្ដាញយុវជនកម្ពុជា (CYN)
២៤. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
២៥. សហគមន៍ដីធ្លីចេកមាស (ស្វាយរៀង)
២៦. សហគមន៍ឆេកូ (ភ្នំពេញ)
២៧. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
២៨. សហគមន៍ដីធ្លីជីខលើ (កោះកុង)
២៩. សហគមន៍ជាំក្រវៀន (ត្បូងឃ្មុំ)
៣០. បណ្ដាញព្រះសង្ឃ ឯករាជ្យដើម្បីយុត្តិធម៌សង្គម (IMNSJ)

៣១. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
៣២. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
៣៣. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៣៤. សហគមន៍ដកពរ (កំពង់ស្ពឺ)
៣៥. សហគមន៍តំបែរ (ត្បូងឃ្មុំ)
៣៦. អង្គការសមធម៌កម្ពុជា (EC)
៣៧. សហគមន៍អភិរក្សព្រៃឈើជីវៈចំរុះ (ស្វាយរៀង)
៣៨. យុវជនជនជាតិដើមភាគតិច ឃុំប្រមេស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ
៣៩. សមាគមឥន្ទ្រទេវី (IDA)
៤០. សមាគមយុវជនខ្មែរ (KYA)
៤១. សហគមន៍ដីធ្លីកោះស្តេច (កោះកុង)
៤២. សហគមន៍នេសាទ កោះស្រឡៅ (កោះកុង)
៤៣. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
៤៤. សហគមន៍ហោងសំណំ (កំពង់ស្ពឺ)
៤៥. សហគមន៍ដីធ្លី (កំពត)
៤៦. អង្គការជំនួយផ្នែក ច្បាប់ដល់ស្ត្រីនិងកុមារ (កោះកុង) LSCW
៤៧. សហគមន៍ដីធ្លីឡពាង (កំពង់ឆ្នាំង)
៤៨. អង្គការការពារសិទ្ធិជន ជាតិដើមភាគតិច (MIRO)
៤៩. អង្គការម្លប់ព្រហ្មវិហារធម៌ (កោះកុង)
៥០. សហគមន៍ដីធ្លីមានជ័យ (ស្វាយរៀង)
៥១. អង្គការមរតក (កោះកុង)
៥២. ចលនាមាតាធម្មជាតិ (MN)
៥៣. សហគមន៍អូរឈើទាល (ព្រះសីហនុ)
៥៤. សហគមន៍ភ្នំបាត (ភ្នំពេញ)
៥៥. សហគមន៍ភ្នំក្រោម (សៀមរាប)
៥៦. សហគមន៍ភូមិដីឆ្នាំង (កំពង់ស្ពឺ)
៥៧. សហគមន៍ភូមិអូរស្វាយ (បន្ទាយមានជ័យ)
៥៨. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)

៥៩. អង្គការពន្លកខ្មែរ (PKH)
៦០. សហគមន៍ព្រែកតាគង់ (ភ្នំពេញ)
៦១. សហគមន៍ព្រែកតានូ (ភ្នំពេញ)
៦២. សហគមន៍ព្រៃឈើពេជ្រចង្វារល្អឆើត (កំពង់ឆ្នាំង)
៦៣. សហគមន៍ព្រៃឡង់ (កំពង់ធំ)
៦៤. សហគមន៍ដីធ្លី ព្រៃពាយ (កំពត)
៦៥. សហគមន៍ផ្លូវរថភ្លើង (ភ្នំពេញ)
៦៦. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
៦៧. សហគមន៍ដីធ្លីរំចេក (សៀមរាប)
៦៨. សមាគមធាងត្នោត (STT)
៦៩. អង្គការគាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា (RCTSO)
៧០. សហគមន៍សាមគ្គី៩ (ភ្នំពេញ)
៧១. សហគមន៍ដីធ្លី សង្គមថ្មី (ពោធិ៍សាត់)
៧២. សហគមន៍ SOS ព្រលានយន្ត ហោះអន្តរជាតិភ្នំពេញ (ភ្នំពេញ)
៧៣. សហគមន៍ស្រែប្រាំង (កំពង់ចាម)
៧៤. សហគមន៍ស្ទឹងបត់ (បន្ទាយមានជ័យ)
៧៥. សហគមន៍ដីធ្លីតានី (សៀមរាប)
៧៦. សហគមន៍ដីធ្លីធ្នង់ (កោះកុង)
៧៧. សហគមន៍ទួលសង្កែ (ភ្នំពេញ)
៧៨. សហគមន៍ត្រពាំងជោរ (កំពង់ស្ពឺ)
៧៩. សហគមន៍ទំនប់ពីរ (ពោធិ៍សាត់)
៨០. សហគមន៍ដីធ្លី១៩៧ (កោះកុង)
៨១. ក្រុមយុវជនជនជាតិដើមភាគតិច (រតនគិរី)
៨២. សហគមន៍ជនជាតិដើមភាគតិចជង (អារ៉ែង)